ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Preliminaire

សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អវតក/កសចស (អបជ ៥៦)
D313/2

តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

**សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អវតក/កសចស (អបជ ៥៦)**

**អង្គបុរេជំនុំជម្រះ**

**ចំពោះមុខ ៖** ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 26 / 06 / 2018
ម៉ោង (Time/Heure): 12:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**សាធារណៈ**

**សេចក្តីសម្រេចលើសំណើអ្នកស្រី អ៊ឹម ចែម ស្នើសុំធ្វើចំណាត់ប្រភេទឯកសារមួយចំនួនដែលបានជ្រើសរើសចេញពីក្នុងសំណុំរឿង ០០៤/១**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីតំណាងអ្នកស្រី អ៊ឹម ចែម**
ប៊ិត ស៊ាងលីម
Wayne JORDASH



ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Porsenchey, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល*សំណើអ្នកស្រី អ៊ឹម ចែម ស្នើសុំធ្វើចំណាត់ប្រភេទឯកសារមួយចំនួន ដែលបានជ្រើសរើសចេញពីក្នុងសំណុំរឿង ០០៤/១* [1] (សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ) និងឧបសម្ព័ន្ធ A[2] និង B[3] នៃឯកសារនេះដែលបានដាក់ដោយ អ៊ឹម ចែម នៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៨។

## I. សេចក្តីផ្តើម

1. សហមេធាវីរបស់ អ៊ឹម ចែម ("សហមេធាវី") បានស្នើសុំឱ្យធ្វើចំណាត់ប្រភេទឯកសារ ៩៥ ច្បាប់ ដែលបានដាក់ក្នុងសំណុំរឿង ០០៤/១ ដោយសហមេធាវី[4] សហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ[5]។

## II. ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ (សំអាងហេតុ) ជាសម្ងាត់ និងជាសាធារណៈ ដែលលើកលែងការចោទប្រកាន់លើ អ៊ឹម ចែម[6]។ នៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៧ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនេះ (សំអាងហេតុ)[7]។ នៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៧ សហមេធាវីបានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកា

---

[1] សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អវតក-កសចស ("សំណុំរឿង ០០៤/១") សំណើអ្នកស្រី អ៊ឹម ចែម ស្នើសុំធ្វើចំណាត់ប្រភេទឯកសារមួយចំនួនដែលបានជ្រើសរើសចេញពីក្នុងសំណុំរឿង ០០៤/១ ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៨ ឯកសារ D313 ("សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ")។

[2] សំណុំរឿង ០០៤/១ សំណើអ្នកស្រី អ៊ឹម ចែម ស្នើសុំធ្វើចំណាត់ប្រភេទឯកសារមួយចំនួនដែលបានជ្រើសរើសចេញពីក្នុងសំណុំរឿង ០០៤/១ ឧបសម្ព័ន្ធ A ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៨ ឯកសារ D313.2 ("ឧបសម្ព័ន្ធ A")។

[3] សំណុំរឿង ០០៤/១, សំណើអ្នកស្រី អ៊ឹម ចែម ស្នើសុំធ្វើចំណាត់ប្រភេទឯកសារមួយចំនួនដែលបានជ្រើសរើសចេញពីក្នុងសំណុំរឿង ០០៤/១, ឧបសម្ព័ន្ធ B, ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៨, ឯកសារ D313.3 ("ឧបសម្ព័ន្ធ B")។

[4] ឧបសម្ព័ន្ធ A។

[5] ឧបសម្ព័ន្ធ B។

[6] សំណុំរឿង ០០៤/១ ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារ D308/3។

[7] សំណុំរឿង ០០៤/១ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៧ ឯកសារ D308/3/1/1។



PRE-TRIAL CHAMBER E.C.C.C.

ដំណោះស្រាយ (សំអាងហេតុ)[8]។ នៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៨ មេធាវីការពារក្តីបានដាក់សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ[9] ដែលសហព្រះរាជអាជ្ញាអន្តរជាតិបានឆ្លើយតបនៅថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៨[10] ដោយយោងទៅតាមសេចក្តីណែនាំរបស់អង្គបុរេជំនុំជម្រះ[11]។

## III. អង្គសេចក្តី

### ក. សារណា

3. អង្គបុរេជំនុំជម្រះបានពិចារណាលើសារណាដែលត្រូវបានដាក់ដោយសហមេធាវី និងសហព្រះរាជអាជ្ញាអន្តរជាតិ។

### ខ. ពិភាក្សា

4. អង្គបុរេជំនុំជម្រះរំឭកឡើងវិញថា យោងតាមវិធាន ៥៦(១) នៃវិធានផ្ទៃក្នុង ៖ “ការស៊ើបសួរមិនត្រូវធ្វើឡើងជាសាធារណៈឡើយ”។ ទីមួយ ការស៊ើបអង្កេតនៅតែត្រូវរក្សាការសម្ងាត់រហូតដល់ពេលមានការស៊ើបមូល ដើម្បីការពារសុចរិតភាព និងផលប្រយោជន៍របស់ភាគី[12]។ ទីពីរ សេចក្តីសម្រេច ដីកាសម្រេច និងការរកឃើញផ្សេងទៀតរបស់សហចៅក្រមស៊ើបអង្កេតត្រូវរក្សាការសម្ងាត់[13]។ ទីបី តាមគោលការណ៍ ឯកសារដែលដាក់ទៅអង្គបុរេជំនុំជម្រះ ត្រូវរក្សាការសម្ងាត់រហូតដល់អង្គជំនុំជម្រះបានធ្វើការសម្រេចលើបញ្ហានោះ[14]។

---

[8] សំណុំរឿង ០០៤/១ ចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៧ ឯកសារ D308/3/1/11។

[9] សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ។

[10] សំណុំរឿង ០០៤/១ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ អ៊ឹម ចែម សុំធ្វើចំណាត់ថ្នាក់ឡើងវិញនូវឯកសារមួយចំនួនដែលបានជ្រើសរើស ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៨ ឯកសារ D313/1។

[11] សំណុំរឿង ០០៤/១ អ៊ីម៉ែលពីអង្គបុរេជំនុំជម្រះផ្ញើជូនភាគីពាក់ព័ន្ធ ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៨។

[12] វិធាន ៥៦ នៃវិធានផ្ទៃក្នុង។ *មើលផងដែរ* សំណុំរឿង ០០៤/១ (អបជ ៤៩) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើការកោសលុប ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១៨ ឯកសារ D309/2/1/7 កថាខណ្ឌ ៣៦។

[13] សេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង អវតក/០០៤/២០០៩/កែសម្រួលលើកទី ២ (“សេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ”) មាត្រា ៥(១)(ច)។ *មើលផងដែរ* សំណុំរឿង ០០៤/១ (អបជ ៤៩) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើការកោសលុប ឬតាមជម្រើសផ្សេងពីនេះ សំណើសុំ

01575089



5. ជាក់ស្តែង អង្គបុរេជំនុំជម្រះអាចធ្វើចំណាត់ប្រភេទឯកសារទាំងនោះឡើងវិញជាឯកសារសាធារណៈ ដោយមានការកោសលុប *ប្រសិនបើចាំបាច់*[15]។ គោលការណ៍ចាំបាច់នៃការធ្វើចំណាត់ប្រភេទ " គឺជាតម្រូវការទាមទារឲ្យមានតុល្យភាពរវាងការសម្ងាត់នៃការស៊ើបអង្កេតរបស់តុលាការ និងផ្នែកផ្សេងទៀតនៃកិច្ចដំណើរការនីតិវិធីតុលាការ ដែលមិនបើកចំហរដល់សាធារណជន តម្រូវការដើម្បីធានាដល់តម្លាភាពនៃកិច្ចដំណើរការនីតិវិធីសាធារណៈ និងសម្រាប់គោលបំណងនៃការអប់រំ និងកេរដំណែល[16]។ កិច្ចដំណើរការនីតិវិធីចំណាត់ថ្នាក់ អាចធ្វើឡើងដោយភាគីដាក់ពាក្យសុំ ប៉ុន្តែនេះមិនមែនជាលក្ខខណ្ឌចាំបាច់ឡើយ។ ជាងនេះទៀត អង្គបុរេជំនុំជម្រះ មានឆន្ទានុសិទ្ធិខ្ពស់លើការវាយតម្លៃនោះ[17]។

6. ក្នុងសំណុំរឿងនេះ រាល់សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ ទាក់ទងនឹងសំណុំរឿង ០០៤/១ នៅតែត្រូវបានការពារដោយកិច្ចស៊ើបសួរដោយសម្ងាត់[18]។ ម្យ៉ាងវិញទៀត ឯកសារមួយ

---

ធ្វើចំណាត់ថ្នាក់ឡើងវិញនៃដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១៨ ឯកសារ D309/2/1/7 កថាខណ្ឌ ២២។

[14] សេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ មាត្រា ៥(១)(ជ)។

[15] សេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ មាត្រា (៤)(ច), មាត្រា ៩(២) និង៩(៣)។

[16] សេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ មាត្រា ១(២)។ *មើលផងដែរ* សំណុំរឿង ០០២ (អបជ ៥៧) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចំពោះដីកាសម្រេចលើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំបំពេញកិច្ចស៊ើបសួរទាក់ទិននឹងទ្រព្យសម្បត្តិទាំងអស់ដែលជនត្រូវចោទមាន ចុះថ្ងៃទី ៤ ខែ សីហា ឆ្នាំ ២០១០ ឯកសារ D193/5/5 កថាខណ្ឌ ១។ សំណុំរឿង ០០៤/១ (អបជ ៤៩) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើការកោសលុប ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១៨ ឯកសារ D309/2/1/7 កថាខណ្ឌ ២៧។ សំណុំរឿង ០០៤/១ (អបជ ៥៤) សេចក្តីសម្រេចលើសំណើរបស់ អ៊ឹម ចែម សុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៃចម្លើយតបរបស់គាត់ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១៨ ឯកសារ D304/6/4 កថាខណ្ឌ ១៨។

[17] សំណុំរឿង ០០៤/១ (អបជ ៥៤) សេចក្តីសម្រេចលើសំណើរបស់ អ៊ឹម ចែម សុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ នៃចម្លើយតបរបស់គាត់ ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១៨ ឯកសារ D304/6/4 កថាខណ្ឌ ២៥។

[18] សំណុំរឿង ០០៤/១ (អបជ ៤៩) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើការកោសលុប ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១៨ ឯកសារ D309/2/1/7។ សំណុំរឿង ០០៤/១ (អបជ ៥៤) សេចក្តីសម្រេចលើសំណើរបស់ អ៊ឹម ចែម

ចំនួនក្នុងចំណោមឯកសារទាំងនោះ អាចទាក់ទងនឹងកិច្ចដំណើរការនីតិវិធីជាបន្តបន្ទាប់ក្នុងសំណុំរឿងផ្សេងទៀត។

7. ទីមួយ អង្គបុរេជំនុំជម្រះពុំមានជំនឿថា ផ្នែកនីមួយៗនៃកិច្ចដំណើរការនីតិវិធី និងសារណានីមួយៗ សុទ្ធតែបំពេញគោលដៅអប់រំ និងកេរដំណែលរបស់ អ.វ.ត.ក ឡើយ[19]។ នេះគឺជាការពិតពាក់ព័ន្ធនឹងលក្ខណៈរបស់ឯកសារមួយចំនួន ដែលត្រូវបានស្នើសុំឱ្យធ្វើចំណាត់ប្រភេទឡើងវិញ (*ឧទាហរណ៍* "សំណើសុំឯកសារចម្លងនៃដីកាកោះហៅរបស់អ្នកស្រី អ៊ឹម ចែម ឲ្យមកបង្ហាញខ្លួនជាលើកដំបូង នៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤"[20] "សំណើរបស់អ្នកស្រី អ៊ឹម ចែម ស្នើសុំច្បាប់ថតចម្លងនៃឯកសារ D123/1/5.1c ដែលអាចអានបាន ដាក់បញ្ចូលទៅក្នុងសំណុំរឿង"[21] "លិខិតរបស់អ្នកស្រី អ៊ឹម ចែម ស្នើសុំពេលវេលាបន្ថែមក្នុងការឆ្លើយតបទៅនឹងលិខិតរបស់លោកចៅក្រម ទាក់ទងនឹងការរៀបចំចូលបង្ហាញខ្លួនលើកដំបូងរបស់អ្នកស្រី អ៊ឹម ចែម"[22] ឬ "សំណើសុំដាក់ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ជាភាសាអង់គ្លេស មុននឹងដាក់អត្ថបទបកប្រែជាភាសាខ្មែរតាមក្រោយ"[23]...)។

8. ទីពីរ នៅពេលប្រឈមនឹងបញ្ហានៃការរក្សាតុល្យភាពផលប្រយោជន៍ អង្គបុរេជំនុំជម្រះយល់ឃើញថា គ្មានឯកសារណាមួយក្នុងឧបសម្ព័ន្ធ A និង B ដែលទាមទារនូវការផ្សព្វផ្សាយជាសាធារណៈភ្លាមៗ និងពេញលេញឡើយ។ ក្រៅពីនេះ ឯកសារមួយចំនួនក្នុងចំណោមឯកសារទាំងនោះត្រូវបានផ្សព្វផ្សាយជាសាធារណៈរួចទៅហើយ[24] និងបានបំពេញគោលដៅអប់រំ។

9. ចុងបញ្ចប់ យោងតាមមាត្រា ១២(២) នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង "ការិយាល័យតុលាការចុងក្រោយដែលបានទទួលសំណុំរឿង ត្រូវធ្វើ

---

សុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៃចម្លើយតបរបស់គាត់ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១៨ ឯកសារ D304/6/4។

[19] សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ កថាខណ្ឌ ១១-១៤។

[20] ឧបសម្ព័ន្ធ A លេខ ១០។

[21] ឧបសម្ព័ន្ធ A លេខ ២៣។

[22] ឧបសម្ព័ន្ធ A លេខ ៧។

[23] ឧបសម្ព័ន្ធ A លេខ ៤៧។

[24] ឧបសម្ព័ន្ធ B លេខ ៣៨ (D285) សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ កថាខណ្ឌ ២៤ *ដែលយោងដល់*ឧបសម្ព័ន្ធ B លេខ ១៥ (D238)។

ការពិនិត្យឡើងវិញលើសន្តិសុខនៃការធ្វើចំណាត់ប្រភេទកំណត់ត្រាក្នុងសំណុំរឿងនោះ”។ ផ្អែកតាមភារកិច្ចរបស់ខ្លួន អង្គបុរេជំនុំជម្រះអាចនឹងត្រូវធ្វើការពិនិត្យឡើងវិញរបៀបនេះលើបណ្ណសារសំណុំរឿង ០០៤/១ នៅពេលក្រោយ។

10. ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា រាល់ការស្នើសុំឲ្យធ្វើចំណាត់ប្រភេទឯកសារឡើងវិញដោយសហមេធាវី សុទ្ធតែមិនចាំបាច់នៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះ និងសូមបដិសេធសំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញនេះ។

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ ៖**

**បដិសេធសំណើនេះ។**

យោងតាមវិធាន ៧៧ (១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះមិនអាចប្តឹងឧទ្ធរណ៍បានឡើយ។

**រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៨**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Olivier BEAUVALLET** **ន័យ ថុល** **Kang Jin BAIK** **ហួត វុទ្ធី**